**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
លេខ ០០៧៥ អបស.អឧម

ថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល
**ជម្រាបជូន**
**- ឯកឧត្តម លោក លោកស្រីប្រធាន អង្គភាពថ្នាក់កណ្ដាល**
**- ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការផ្សព្វផ្សាយព័ត៌មានស្ដីពីអាហារូបករណ៍នូវែលសេឡង់ (MNZS ) សម្រាប់ឆ្នាំសិក្សា២០២៦។
**យោង ៖** លិខិតលេខ ៩៦៣ កបទ.សអ/អបប២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋាភិបាលនូវែលសេឡង់នឹងផ្ដល់អាហារូបករណ៍ Manaaki New Zealand Scholarships (MNZS) ថ្នាក់ឧត្តមសិក្សាជូនកម្ពុជា( ទាំងក្នុងវិស័យសាធារណៈ និងឯកជន ) ចំនួន ៣៥កន្លែង សម្រាប់ឆ្នាំសិក្សា២០២៦ លើមុខវិជ្ជាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ សន្តិសុខស្បៀងនិងកសិកម្ម ថាមពលកកើតឡើងវិញ អភិបាលកិច្ច និងការបង្រៀនភាសាអង់គ្លេស(TESOL) ទៅបន្តការសិក្សា នៅតាមសាកលវិទ្យាល័យនានា នៅប្រទេសនូវែលសេឡង់។អាហារូបករណ៍នេះនឹងរួមបញ្ចូលថ្លៃសិក្សា ថ្លៃទិដ្ឋាការ ប្រាក់ឧបត្ថម្ភនៅពេលទៅដល់ ប្រាក់ឧបត្ថម្ភ សម្រាប់ការចំណាយប្រចាំថ្ងៃ និងសំបុត្រយន្តហោះទៅមក។

សម្រាប់មន្ត្រីដែលត្រូវចូលរួមវគ្គសិក្សាខាងលើ ត្រូវដាក់ពាក្យចូលរួមប្រកួតប្រជែងដោយផ្ទាល់តាមរយៈគេហទំព័រ www.nzscholarships.govt.nz/apply-online ដែលការទទួលពាក្យនឹងចាប់ផ្ដើមពីថ្ងៃទី១ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥។ សម្រាប់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងការបំពេញសំណុំបែបបទដាក់ពាក្យ សូមទាក់ទងការិយាល័យ IDP Education (Cambodia) សាខាទួលទំពូង ឬតាមរយៈអ៊ីមែល nzscholarshipsinfo@idp.com ឬលេខទូរសព្ទ ០២៣ ២២២ ០៦៣។

នៅពេលទទួលបានការជ្រើសរើស សាមីខ្លួនត្រូវសុំការអនុញ្ញាតមកក្រសួង តាមរយៈប្រធានអង្គភាព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ធ្វើការផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទ និងស្របតាមលក្ខខណ្ឌជ្រើសរើសដាក់ពាក្យចូលរួមឱ្យបានទាន់ថ្ងៃកំណត់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការគោរពពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

**វេជ្ជ. ម៉ី សំបូរ**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-ឯកសារ កាលប្បវត្តិ

**NOTE NO: 2025/C/002**

The New Zealand Embassy presents its compliments to the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia and has the honour to advise of the Manaaki New Zealand Scholarships for postgraduate study selection year 2025 supported through the New Zealand International Development Cooperation Programme within the Ministry of Foreign Affairs and Trade.

Cambodia has been allocated up to thirty-five scholarships this year. These scholarships are for candidates to undertake full-time postgraduate study programmes commencing in the 2026 academic year at one of the following tertiary education institutions in New Zealand: Auckland University of Technology, Lincoln University, Massey University, University of Auckland, University of Canterbury, University of Otago, University of Waikato, Victoria University of Wellington, Southern Institute of Technology, Unitec Institute of Technology, and Wintec - Waikato Institute of Technology.

This scholarship is open to participants from both public and private sector organisations in Cambodia. To be eligible for shortlisting, candidates would need to meet the Manaaki New Zealand Scholarship eligibility criteria. The priority areas for the 2025 selection round include Climate Change and the Environment, Disaster Management, Food Security and Agriculture, Renewable Energy, Governance, and Teaching English to Speakers of Other Languages (TESOL).

Each scholarship will cover full tuition fees, visa application fees, establishment allowances, stipends for routine expenditure, and return airfares (for initial arrival to New Zealand and final departure to home country).

The Embassy respectfully requests the Ministry of Foreign Affairs and International Cooperation inform the relevant ministries of this opportunity.

Applicants are invited to apply online at www.nzscholarships.govt.nz/apply-online. The online application portal will be open from 1 February 2025 to 28 February 2025. For further information, please contact the Manaaki New Zealand Scholarships Office at IDP Education (Cambodia) within the ACE Tuol Tom Poung Campus via email at nzscholarshipsinfo@idp.com or by telephone at (+855) 23 222 063.

The New Zealand Embassy takes this opportunity to renew to the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia the assurances of its highest consideration.

NEW ZEALAND EMBASSY BANGKOK

New Zealand Embassy
Accredited to the Kingdom of Cambodia
Resident in Bangkok

21 January 2025